រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ : ០៤៤៧ / ១១ / ស.ប.ក. អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែ មីនា ឆ្នាំ ២០១១

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកុម្ភៈ ឆ្នាំ២០១១
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១១

(០១/០២/២០១១-២៨/០២/២០១១)

ខែកុម្ភៈឆ្នាំ២០១១នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមទិសដៅពហុវិស័យ ដែលបានដាក់ចេញកាលពីខែមករាកន្លងទៅ សំដៅរួមចំណែករក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង សកម្មភាពនិងលទ្ធផលការងារដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានខិតខំអនុវត្តនៅក្នុងខែកុម្ភៈនេះរួមមាន :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ក្នុងខែនេះ ក៏ដូចជាបណ្តាខែមុនៗ ពួកឈ្មួញគ្រឿងញៀននៅតែបន្តធ្វើការចរាចរគ្រឿងញៀននៅតាមតំបន់ព្រំដែន ។ **កត់សំគាល់** នៅតំបន់ព្រំដែនភាគពាយ័ព្យសមត្ថកិច្ចបានរកឃើញ**៦**ករណី ក្នុងនោះ ខេត្តកោះកុង(១ករណី) ខេត្តបន្ទាយមានជ័យ(៣ករណី) និងខេត្តប៉ៃលិន(២ករណី) ។ នៅតំបន់ព្រំដែនភាគឥសានសមត្ថកិច្ចបានរកឃើញ**៣**ករណី ក្នុងនោះ នៅខេត្តស្ទឹងត្រែង(១ករណី) ខេត្តក្រចេះ(១ ករណី) និងខេត្តកំពង់ធំ(១ករណី) ។

ដោយឡែក នៅរាជធានីភ្នំពេញសមត្ថកិច្ចបានរកឃើញការចរាចរជួញដូរចែកចាយនិងប្រើប្រាស់គ្រឿងញៀន ចំនួន ៣១ករណី និងមានករណីមួយចំនួនទៀតសមត្ថកិច្ចបានរកឃើញនៅបណ្តាខេត្តផ្សេងៗ ដូចជា ខេត្តកំពង់ចាម ខេត្តព្រះសីហនុ ខេត្តកំពត ដែលជាហេតុធ្វើឱ្យការបង្ក្រាបបទល្មើសគ្រឿងញៀនក្នុងខែកុម្ភៈនេះ មានការកើនឡើង១៣ករណី ស្មើនឹងជាង៣៩% បើប្រៀបធៀបនឹងខែមករាកន្លងទៅ ដែលសមត្ថកិច្ចរកឃើញនិងបង្ក្រាបបាន ៣៣ ករណី ។ ក្នុងចំណោមករណីដែលបង្ក្រាបខាងលើ មានមួយករណី**ហេរ៉ូអ៊ីន** បានធ្វើសកម្មភាពនាំឆ្លងកាត់តាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ក្នុងទិសដៅឆ្ពោះទៅកាន់ប្រទេសអូស្ត្រាលី ប៉ុន្តែត្រូវកម្លាំងមានសមត្ថកិច្ចចម្រុះនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញធ្វើការបង្ក្រាបបានទាន់ពេលវេលា ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

*-ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើកកម្ពស់វិធានការពហុវិស័យក្នុងការត្រួតពិនិត្យគ្រឿងញៀន ជាអាទិ៍ :

-ការណែនាំឱ្យសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការដៃគូជាតិនិងអន្តរជាតិដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ និងការពិភាក្សាស្វែងរកវិធីសាស្ត្រដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ ។

-ការណែនាំឱ្យរៀបចំកិច្ចប្រជុំពិភាក្សា អំពីកិច្ចដំណើរការរៀបចំមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-ការណែនាំឱ្យចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការសាកល្បងសកម្មភាពថែទាំ ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍ នៅខេត្តបន្ទាយមានជ័យដែលជាខេត្តអនុវត្តផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន ។

-ការណែនាំឱ្យបន្តការចូលរួមក្នុងគណៈកម្មការរៀបចំកិច្ចប្រជុំលើកទី៨ នៃគណៈកម្មាធិការស្វែងរកការពិត ដើម្បីប្រយុទ្ធប្រឆាំងការគំរាមកំហែងដោយគ្រឿងញៀន ។

-ការណែនាំឱ្យរៀបចំកម្មវិធីជួបពិភាក្សាការងារជាមួយប្រតិភូកាកបាទក្រហមអ៊ីតាលី (កម្មវិធីនេះ បានរៀបចំទទួលដោយឯកឧត្តម **កៅ ខុនដារ៉ា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅថ្ងៃទី១០/០២/២០១១) ។

### ១.ការកាត់បន្ថយតម្រូវការគ្រឿងញៀន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំនិងសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ធ្វើការផ្សព្វផ្សាយអប់រំ ដើម្បីលើកកំពស់ការយល់ដឹងអំពីច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀន រួមទាំងបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ តាមរយៈសកម្មភាព ជាអាទិ៍ :

-ការផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍CTN ដែលនៅក្នុងខែកុម្ភៈនេះ ៖

▯អគ្គលេខាធិការដ្ឋាន អជបគញ បានផ្តល់កិច្ចសម្ភាសន៍ក្រោមប្រធានបទស្តីពី ការអប់រំយុវវ័យឱ្យចៀសឆ្ងាយពីគ្រឿងញៀន កាលពីថ្ងៃទី០២ខែកុម្ភៈឆ្នាំ២០១១ ។

▯ក្រសួងយុត្តិធម៌ បានផ្តល់កិច្ចសម្ភាសន៍ក្រោមប្រធានបទស្តីពី ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១១ ។

-ការជួយធ្វើអន្តរាគមន៍ឱ្យ **សមាគមយុវជនខ្មែរ** បានធ្វើសកម្មភាពអប់រំបង្ការការប្រើបំពានគ្រឿងញៀន នៅវិទ្យាល័យ **ហ៊ុន សែន** ភ្នំពេញថ្មី, វិទ្យាល័យ **ហ៊ុន សែន** ជម្ពូវ័ន និងនៅ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ។

-ការចូលរួមនៅក្នុងពិធីបើកវគ្គបណ្តុះបណ្តាលជនបង្គោលបណ្តាញយុវជន ចំនួន៥២រូប នៅឃុំព្រែករកា និងឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹងខេត្តកណ្តាលរបស់អង្គការពន្លឺកុមារកម្ពុជា ដែលមានការគាំទ្រពីអង្គការCCJAP និងអង្គការAusAID ក្រោមគំរោង"អន្តរាគមន៍ដើម្បីសុវត្ថិភាពសហគមន៍មូលដ្ឋាន"ដំណាក់កាលទី២ កាលពីថ្ងៃទី២០ខែមករាឆ្នាំ២០១១និង

ចូលរួមក្នុងវេទិកាពិភាក្សាយុវជន ក្រោមប្រធានបទ "រួមសាមគ្គីគ្នាធ្វើឱ្យសហគមន៍យើងមានសុវត្ថិភាព" កាលពីថ្ងៃទី១៣ខែកុម្ភៈឆ្នាំ២០១១ របស់អង្គការពន្លឺកុមារកម្ពុជា ផងដែរ ដែលមានការគាំទ្រពីអង្គការ**IOGT-NTO MOVEMENT** និង **Forum Syd** របស់ប្រទេសស៊ុយអែត តាមរយៈគំរោង "ត្រួតពិនិត្យការប្រើប្រាស់គ្រឿងញៀនដោយផ្អែកលើសហគមន៍" ដោយមានការអញ្ជើញចូលរួមពីប្រធានក្រុមប្រឹក្សាឃុំព្រែកស្លែង ប្រធានក្រុមប្រឹក្សាស្រុកកណ្ដាលស្ទឹង សមាជិកក្រុមប្រឹក្សាឃុំ នគរបាលប៉ុស្តិ៍ ក្រុមជនបង្គោលក្នុងឃុំគោកត្រប់ និង ឃុំព្រែកស្លែង ក្រុមយុវជនស្ម័គ្រចិត្ត និង តំណាងប្រជាជន យុវជន មកពីភូមិព្រែកស្លែង ភូមិពង់ចាន ភូមិប្រាសាទ និង ភូមិតាចុក សរុបប្រមាណជាង ៥០០ នាក់ ។ ក្នុងចំណោមកម្មវិធីនៃវេទិកាពិភាក្សានេះ បានកត់សំគាល់ឃើញមាន ការសំដែងរឿងខ្លីអប់រំពីគ្រឿងញៀនដោយក្រុមយុវជនស្ម័គ្រចិត្ត, កម្មវិធីសំណួរ-ចម្លើយពាក់ព័ន្ធនឹងគ្រឿងញៀន គ្រឿងស្រវឹង និងសុវត្ថិភាពសហគមន៍, កម្មវិធីចម្រៀងកំដរអារម្មណ៍ និងចម្រៀងអប់រំពីបញ្ហាគ្រឿងញៀន, ចំណាប់អារម្មណ៍និងមតិអប់រំដោយលើកយកចំណុចសំខាន់ៗពាក់ព័ន្ធនឹងការបង្ការ ការប្រើបំពានគ្រឿងញៀន គ្រឿងស្រវឹង និងការកសាងសហគមន៍មានសុវត្ថិភាព ។

-ការផ្ដល់ជូននូវឯកសារនានាពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ដល់បណ្ណាល័យរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សំរាប់បំរើជូន សាស្ត្រាចារ្យ សិស្ស និស្សិត និង សាធារណជន ចូលមកសិក្សាស្រាវជ្រាវ ។

សកម្មភាពការងារទាំងអស់ខាងលើ រួមបញ្ចូលការងារផ្សព្វផ្សាយអប់រំប្រចាំខែ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្តនានា មានមន្ត្រីរាជការនិងប្រជាពលរដ្ឋ ចូលរួមសរុបចំនួន **១២.៣២៨** នាក់ ។

## ២.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

ខែកុម្ភៈឆ្នាំ២០១១ បង្ក្រាបបទល្មើសបាន **៤៦ ករណី**, ឃាត់ខ្លួនមនុស្ស **១១៣ នាក់**( ប្រុស ៨៤ នាក់, ស្រី ២៩ នាក់) ក្នុងនោះ ជនជាតិ **ខ្មែរ** ១០៦ នាក់( ប្រុស ៧៩ នាក់, ស្រី ២៧ នាក់) **វៀតណាម** ៧ នាក់( ប្រុស ៥ នាក់, ស្រី ២ នាក់) ។

**វត្ថុតាងចាប់យក** រួមមាន : មេតំហ្វេតាមីនWY 19.174 គ្រាប់, មេតំហ្វេតាមីនICE 135,23 ក្រាម, ហេរ៉ូអ៊ីន 388,72 ក្រាម, ម្សៅពណ៌ស 1,4 ក្រាម, ម្សៅពណ៌សគ្មានសារធាតុញៀន 0,27 ក្រាម, ជញ្ជីង ៤, អាវុធខ្លី ៣ ដើម, រថយន្ត ១ គ្រឿង, ម៉ូតូ ៣ គ្រឿង និង ឧបករណ៍វេចខ្ចប់និងប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

ដោយឡែក សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយស្ថាប័នមានសមត្ថកិច្ច រួមមាន ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ប្រចាំខែកុម្ភៈឆ្នាំ២០១១នេះ សរុបមានចំនួន **1.889.739 Kg** ។

## ៣.ការព្យាបាល ស្តារនីតិសម្បទា និង ការកាត់បន្ថយគ្រោះថ្នាក់

### .ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

១-អនុវត្តតាមខ្លឹមសារអនុក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅថ្ងៃទី០៤ខែកុម្ភៈឆ្នាំ២០១១ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់តំណាងចូលរួមនៅក្នុងកិច្ចប្រជុំអន្តរក្រសួង ដែលរៀបចំដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ដើម្បីពិភាក្សាអំពីការបន្តការរៀបចំបង្កើត និងដំណើរការគ្រប់គ្រងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ឱ្យបានល្អប្រសើរតាមគោលការណ៍រួមរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ អង្គប្រជុំបានឯកភាពគ្នាដូចតទៅ :

-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នឹងប្រគល់ដីទីតាំងសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ស្ថិតនៅភូមិត្រពាំងមូល ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជូនទៅក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ជាម្ចាស់កម្មសិទ្ធិ ។

-ភាគីទាំងពីរ( ក្រសួងសង្គមកិច្ច និង អជបគញ) បន្តជំរុញការដាក់បញ្ចូលសំណើជំនួយកសាងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទៅក្នុងគំរោងស្នើសុំជំនួយទ្វេភាគីពីរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម (គំរោងអាទិភាព) ដែលនឹងត្រូវអនុម័តនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសកម្ពុជា-វៀតណាម នាអំឡុងខែមីនាឆ្នាំ២០១១ នៅប្រទេសវៀតណាម ក្នុងនោះ មន្ត្រីជំនាញរបស់ស្ថាប័នទាំងពីរនឹងបន្តសហការសម្របសម្រួលជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និងភាគីវៀតណាមជាម្ចាស់ជំនួយ ដើម្បីឱ្យគំរោងនេះទទួលបានការអនុម័តជាស្ថាពរពីកិច្ចប្រជុំ ។

-បង្កើតអនុគណៈកម្មការជួយលើការបង្កើត និងដំណើរការមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា និងមានក្រសួងសមាជិកពាក់ព័ន្ធចូលរួម ហើយត្រូវបានពិនិត្យ សម្រេច ដោយឯកឧត្តមប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

២-តបតាមការអញ្ជើញរបស់មន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ ដែលជាខេត្តដកពិសោធន៏លើការអនុវត្តន៏ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់មន្ត្រីជំនាញ០១រូប ទៅចូលរួមក្នុងពិធីផ្សព្វផ្សាយផែនការសាកល្បងសកម្មភាពថែទាំព្យាបាលអ្នកប្រើគ្រឿងញៀនដោយផ្អែកលើសហគមន៏ ក្រោមការគាំទ្រដោយអង្គការUNODC តាមរយៈគំរោង **Treatnet II** កាលពីថ្ងៃទី១១ខែកុម្ភៈឆ្នាំ២០១១ នៅមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ ក្នុងនោះ ៖

សមាសភាពចូលរួមក្នុងកិច្ចប្រជុំ រួមមាន តំណាងUNODCនៅភ្នំពេញ, អនុប្រធានមន្ទីរសុខាភិបាល មន្ត្រីពាក់ព័ន្ធនៃមន្ទីរសុខាភិបាលខេត្ត, មន្ត្រីតំណាងមន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្ត, មន្ត្រីតំណាងសាលាស្រុក/ក្រុង, ក្រុមប្រឹក្សាឃុំ/សង្កាត់, នគរបាលប៉ុស្តិ៍, មន្ត្រីមណ្ឌលសុខភាព និងអង្គការពាក់ព័ន្ធមួយចំនួនសរុបជាង ៥0 នាក់ ។

ខ្លឹមសារសំខាន់គឺ ការពន្យល់ណែនាំនិងពិភាក្សាជាមួយក្រុមមន្ត្រីនិងសមត្ថកិច្ចពាក់ព័ន្ធនៅតាមមូលដ្ឋានគោលដៅឱ្យបានយល់ច្បាស់ពីគោលការណ៏នៃការថែទាំព្យាបាល កិច្ចដំណើរការកម្មវិធី វិធីបំពេញទម្រង់ឯកសារនានា រួមទាំងព័តិមានផ្សេងៗរបស់អ្នកញៀនដែលចាំបាច់ក្នុងការជួយដល់ការថែទាំ ព្យាបាល និងការប្រើប្រាស់ឯកសារដែលបានរៀបចំរួចមួយចំនួនទៀត ដូចជា សៀវភៅចុះឈ្មោះ ឯកសារពិនិត្យជម្ងឺ ឯកសារតាមដានជម្ងឺ របាយការណ៏ និងប័ណ្ណផ្តល់ព័តិមានតូចសំរាប់ជួយឱ្យអ្នកញៀនអាចបង្ការនិងថែទាំខ្លួនពីការលាប់ឡើងវិញ ។

ទីកន្លែងសំរាប់អនុវត្តកម្មវិធីសាកល្បងគឺ មន្ទីរពេទ្យបង្អែកសិរីសោភ័ណ មន្ទីរពេទ្យបង្អែកប៉ោយប៉ែត មណ្ឌលសុខភាពប៉ោយប៉ែត មណ្ឌលសុខភាពព្រះពន្លា មណ្ឌលសុខភាពអូរអំបិល មណ្ឌលសុខភាពទឹកថ្លា មណ្ឌលសុខភាពកំពង់ស្វាយ មណ្ឌលសុខភាពបន្ទាយនាង មណ្ឌលសុខភាពអូរបីជាន់ និង មណ្ឌលសុខភាពម៉ាឡៃ ដោយអង្គការUNODCបានផ្តល់នូវកុំព្យូទ័រលើតុចំនួន៤គ្រឿង, ម៉ាស៊ីនព្រីនចំនួន៤គ្រឿង, UPSចំនួន៤គ្រឿង, តុចំនួន១០, កៅអីចំនួន៣0, និង ទូរដាក់ឯកសារចំនួន១២ ។

នៅពេលអនុវត្តកម្មវិធីសាកល្បងសកម្មភាពថែទាំ ព្យាបាលអ្នកប្រើគ្រឿងញៀនដោយផ្អែកលើសហគមន៏នេះចប់ត្រូវរៀបចំសិក្ខាសាលា ដោយជ្រើសរើសឱ្យក្រុមជនរងគ្រោះ ក្រុមគ្រួសារជនរងគ្រោះ និងមន្ត្រីដែលទទួលខុសត្រូវអនុវត្តផ្ទាល់

លើកឡើងបកស្រាយបង្ហាញដើម្បីជាបទពិសោធន៍និងលទ្ធផលជាក់ស្តែង ។

**.ការកាត់បន្ថយគ្រោះថ្នាក់**

ដើម្បីជំរុញការងារកាត់បន្ថយគ្រោះថ្នាក់ ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំកិច្ចប្រជុំមួយកាលពីថ្ងៃទី១៤ខែមករាឆ្នាំ២០១១ នៅសណ្ឋាគារសាន់វ៉េ ដែលមានក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការជាដៃគូជាតិនិងអន្តរជាតិចូលរួមសរុបចំនួន ៣០ នាក់ ដើម្បីពិភាក្សាអំពីដំណើរការត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ និងការស្វែងរកវិធីសាស្ត្រនានាដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ក្នុងនោះ ៖

ពាក់ពន្ធ័នឹងដំណើរការរៀបចំសិក្ខាសាលា អង្គប្រជុំបានសម្រេចបង្កើតគណៈកម្មការសំរាប់រៀបចំសិក្ខាសាលាឱ្យធានាបាននូវប្រសិទ្ធភាពនិងទទួលបាននូវលទ្ធផលដូចការគ្រោងទុក ដោយរៀបចំឱ្យមានកិច្ចប្រជុំជាបន្តបន្ទាប់រវាងស្ថាប័នរបស់រាជរដ្ឋា-ភិបាលជាមួយអង្គការដៃគូ ដើម្បីស្វែងរកការគាំទ្រទាំងផ្នែកបច្ចេកទេសនិងថវិកាសម្រាប់ ដំណើរការរៀបចំសិក្ខាសាលា ក៏ដូចជាសម្រាប់ការអនុវត្តន៏កម្មវិធី ។

ពាក់ព័ន្ធនឹងការលើកកម្ពស់គុណភាពសេវាព្យាបាលតាមសហគមន៍ អង្គប្រជុំបានឯកភាពបង្កើតក្រុមការងារដើម្បីពិភាក្សាកែសម្រួលនិងជំរុញក្រុមការងារបច្ចេកទេសទទួលបន្ទុកកិច្ចការព្យាបាលនិងស្តារនីតិសម្បទា ដែលមានស្រាប់ឱ្យដំណើរការទៅបានដោយរលូននិងមានប្រសិទ្ធភាព ។

**ជាមួយនេះដែរ** តាមការស្នើសុំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :

- -បានចាត់មន្រ្តីបង្គោលមួយរូបសម្រាប់ទំនាក់ទំនងការងារហិរញ្ញវត្ថុ(Focal Point) និងការងារត្រួតពិនិត្យនិងវាយតម្លៃការងារត្រួតពិនិត្យនិងវាយតម្លៃ(Monitoring and Evaluation)នៃមូលនិធិសកលជុំទី៩ ។
- -បានចាត់បញ្ជូនមន្រ្តីជំនាញ ០១ រូប ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយនិងពង្រឹងការអនុវត្តន៏សេចក្តីប្រកាសលេខ ៦៦ របស់រាជរដ្ឋាភិបាល កាលពីថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០១១ នៅសណ្ឋាគារសាន់វ៉េ ក្នុងគោលបំណងជំរុញការប្រើប្រាស់ស្រោមអនាម័យ១០០% ក្នុងការកាត់បន្ថយការឆ្លងរីករាលដាលនៃមេរោគអេដស៍និងជម្ងឺអេដស៍ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**៤.ការពង្រឹងសមត្ថភាពមន្រ្តីអនុវត្តច្បាប់**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តកិច្ចសហការជាមួយអង្គការដៃគូនានា តាមរយៈសកម្មភាពដូចតទៅ :

១-នៅថ្ងៃទី២៤-២៨ខែកុម្ភៈឆ្នាំ២០១១ ក្រោមជំនួយឧបត្ថម្ភរបស់អង្គការAusAIDS តាមរយៈអង្គការFHI អគ្គលេខាធិការដ្ឋាន អជបគញ បានរៀបចំកិច្ចប្រជុំក្រុមការងារជាលើកទី៣របស់ខ្លួន ដើម្បីកែសម្រួលឯកសារនិងកម្មវិធី នៃវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពអនុវត្តច្បាប់គ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ ដែលក្នុងនោះក្រុមការងារនឹងធ្វើការរៀបចំមេរៀនមួយបន្ថែមទៀតសំរាប់ការបង្រៀន សរុបទាំងអស់មាន៩មេរៀនគឺ មេរៀនទី១.ស្តីពីព័តិមានជាមូលដ្ឋានអំពីគ្រឿងញៀន, ទី២.ការកើតមានឡើង/ប្រេវ៉ាឡង់នៃមេរោគអេដស៍/ជម្ងឺអេដស៍និងឥទ្ធិពលដ៏ខ្លាំងក្លារបស់វាទៅបុគ្គលសហគមន៍និងប្រជាជាតិ, ទី៣.យុទ្ធសាស្ត្រផ្សេងៗជួយកាត់បន្ថយការចម្លងមេរោគអេដស៍ដល់មន្រ្តីអនុវត្តច្បាប់ក្នុងអំឡុងពេលប្រតិបត្តិការ, ទី៤.នីតិវិធីគ្រប់គ្រងការឆ្លងមេរោគអេដស៍, ទី៥.កម្ម

វិធីគាំទ្រដែលមានគោលបំណងក្នុងការកាត់បន្ថយការឆ្លងរាលដាលនៃមេរោគអេដស៍ ក្នុងចំណោមអ្នកចាក់គ្រឿងញៀន, ទី៦.ការជួយសង្គ្រោះអ្នកចាក់គ្រឿងញៀននៅពេលមានបញ្ហា, ទី៧.ការលើកកំពស់សមត្ថភាពការយល់ដឹងពីច្បាប់គ្រឿងញៀន, ទី៨.ការងារវាយតម្លៃ ការប្រមូល ការរក្សាទុក និងការផ្តល់ព័ត៌មានទៅដល់អ្នកដទៃទៀត និង ទី៩.មេរៀនស្តីពីកិច្ចសហការ-គន្លឹះទៅរកភាពជោគជ័យ ។

២-មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អជបគញ បានចុះទៅធ្វើការសិក្សាស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងសារធាតុគីមីផ្សំគ្រឿងញៀននៅខេត្តកណ្តាល ដោយប្រើប្រាស់វិធីសាស្ត្រពីរគឺ ទី១) ធ្វើការសិក្សានិងប្រមូលព័ត៌មានតាមរយៈការជួបសម្ភាសន៍ជាមួយមន្ត្រីពាក់ព័ន្ធសំខាន់ៗសរុបចំនួន ២៧៩ នាក់ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកណ្តាល និង ទី២) ធ្វើការសិក្សានិងប្រមូលព័ត៌មានតាមរយៈកម្រងសំណួរ ដើម្បីរៀបចំផែនការសកម្មភាពជាក់លាក់មួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងគោលដៅពង្រឹងការងារគ្រប់គ្រងនិងត្រួតពិនិត្យការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀន នៅតាមបណ្តាស្ថាប័នពាក់ព័ន្ធ ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ។

**ក្រៅពីការងារខាងលើ** អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន :

-អនុវត្តនូវកម្មវិធីសរសើរលើកទឹកចិត្ត តាមរយៈការផ្តល់នូវវិញ្ញាបនបត្របញ្ជាក់ការសិក្សា ដល់សិក្ខាកាមជាមន្ត្រីអនុវត្តច្បាប់នៅខេត្តសៀមរាបចំនួន៣៦រូប ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពី "ការអនុវត្តន៍ច្បាប់ដោយប្រព័ន្ធកុំព្យូទ័រ (CBT)" ។

-ចាត់តាំងមន្ត្រីជំនាញ០១រូប ចូលរួមធ្វើជាចំណុចកណ្តាល(Focal Point) សម្រាប់ទំនាក់ទំនងការងារជាមួយក្រុមការងារសម្របសម្រួល វ៉ែន-កម្ពុជា(CWCU) នៃរដ្ឋបាលព្រៃឈើ ។

-រៀបចំទទួលក្រុមប្រតិភូនៃអង្គភាពត្រួតពិនិត្យគ្រឿងញៀនសហព័ន្ធរុស្ស៊ី ដែលនឹងមកជួយបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្ពុជា ពីថ្ងៃទី២១-២៥ ខែមីនា ឆ្នាំ២០១១ ។

ជាមួយនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏បានអនុញ្ញាតជាគោលការណ៍ឱ្យមន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អជបគញ ចូលរួមក្នុងកម្មវិធី "កិច្ចសហការធ្វើកោសល្យវិច័យជាលក្ខណៈអន្តរជាតិ(International Collaborative Exercises Ice)" របស់ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ(UNODC) ដែលមានគោលបំណងបង្កើននូវគុណភាពនិងលើកកម្ពស់ការអភិវឌ្ឍន៍ ការធ្វើកោសល្យវិច័យលើសារធាតុញៀនរបស់មន្ទីរពិសោធន៍គ្រឿងញៀនថ្នាក់ជាតិនៅទូទាំងសកលលោក ។

**ដោយឡែក** ជាមួយបណ្តាប្រទេសក្នុងតំបន់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជូនមន្ត្រីជំនាញទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើការងារត្រួតពិនិត្យសារធាតុគីមីផ្សំ និងការស៊ើបអង្កេតមន្ទីរពិសោធន៍លួចលាក់ ដែលរៀបចំដោយបណ្ឌិត្យសភាអនុវត្តច្បាប់អន្តរជាតិ(International Law Enforcement Academy. ILEA) នៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី១០-២១ខែមករាឆ្នាំ២០១១ ។ តាមរយៈលទ្ធផលនៃវគ្គបណ្តុះបណ្តាលនេះ មន្ត្រីជំនាញបានយល់ ដឹងពីគ្រោះថ្នាក់និងការបង្វែរសារធាតុគីមីដើម(Precursor) នៅមន្ទីរពិសោធន៍លួចលាក់, ការបន្លំឈ្មោះសារធាតុគីមីដើមតាមរយៈការច្រកក្នុងធុងសារ

ធាតុគីមីឈ្មោះផ្សេង, ការខ្ចីអាជ្ញាបណ្ណ័ពីក្រុមហ៊ុនផ្សេងដើម្បីងាយនាំចូលសារធាតុគីមីដោយស្របច្បាប់, វិធីសាស្ត្រនៃការញែកសារធាតុគីមីពីថ្នាំផ្តាសាយឬថ្នាំផ្សេងៗទៀត, វិធីសាស្ត្រតាមដានស៊ើបអង្កេតតាមបណ្តាឱសថស្ថាន និងក្រុមហ៊ុន រោងចក្រស្របច្បាប់, វិធីសាស្ត្រតាមដានស៊ើបអង្កេតការបញ្ជាទិញឱសថតាមរយៈអ៊ីនធឺណេត, វិធីសាស្ត្របង្កប់កម្លាំង តាមដានតាមបណ្តាក្រុមហ៊ុនសង្ស័យនិងទិញសារធាតុពីជនល្មើស រួមទាំងការអនុវត្តលំហាត់ជាក់ស្តែងស្តីពីការសួរចម្លើយរកវត្ថុតាង និងបានអនុវត្តលំហាត់ជាក់ស្តែងស្តីពីការធ្វើសមយុទ្ធក្នុងមន្ទីរពិសោធន៍លួចលាក់ ។

### ៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ

ដើម្បីចូលរួមចំណែកក្នុងយន្តការត្រួតពិនិត្យគ្រឿងញៀន ទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនៅក្នុងតំបន់ អនុតំបន់ និង អន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបាន :

១-ចូលរួមក្នុងកិច្ចប្រជុំមន្ត្រីទំនាក់ទំនងគំរោងស្តីពី ភាពជាដៃគូនៃបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ( គំរោងH15) ដែលបានធ្វើឡើងនៅប្រទេសឡាវ នាថ្ងៃទី១៩-២០ខែមករាឆ្នាំ២០១១ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ នាពេលខាងមុខ ។

២-អគ្គលេខាធិការដ្ឋាន អជបគញ ដោយមានការគាំទ្រពីអង្គការUNODC នៅថ្ងៃទី២៤-២៥ខែកុម្ភៈឆ្នាំ២០១១ បានរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់ សំរាប់គំរោងស្តីពីភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (Project Advisory Committee-PATROL) នៅសណ្ឋាគារ Le Royal ។

៣-តាមការស្នើសុំរបស់កម្ពុជា អង្គការUNODCតំបន់ បានឯកភាពគាំទ្រក្នុងការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដោយបានចុះទៅសិក្សាស្វែងយល់អំពីស្ថានភាពគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែន នៅច្រកទ្វារអន្តរជាតិភ្នំដិនខេត្តតាកែវ កាលពីថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០១១ ហើយនិងបន្តចុះទៅសិក្សាស្វែងយល់នៅច្រកទ្វារអន្តរជាតិត្រពាំងផ្លុង ខេត្តកំពង់ចាម កាលពីថ្ងៃទី០២ខែមីនាឆ្នាំ២០១១ ។

### ៦.នីតិកម្ម

ថ្ងៃទី១៧ខែកុម្ភៈឆ្នាំ២០១១ តាមការអញ្ជើញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បានបន្តការប្រជុំជាមួយអន្តរក្រសួង ដើម្បីពិនិត្យលើសេចក្តីព្រាងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

### ៧.ការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន

ដើម្បីជំរុញការអនុវត្តន៍យុទ្ធសាស្ត្រខាងលើ កាន់តែមានប្រសិទ្ធភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុវត្តគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដោយផ្តោតសំខាន់ទៅលើ ការងារប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ដោយបានបង្កើត "ក្រុមប្រឹក្សាយោបល់គាំទ្រសកម្មភាពការងារធ្វើការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា" និងបានធ្វើការប្រជុំពិភាក្សាលើសេចក្តីព្រាង National size estimate of DU population and survey on HIV related risk behavior កាលពីថ្ងៃទី២៣ខែកុម្ភៈឆ្នាំ២០១១ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន អជបគញ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនិងសកម្មភាពនានា ឆ្លើយតបទៅនឹងគោលដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីតំណាង ក្រសួងអប់រំយុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ចអតីតយុទ្ធជន

និងយុវនីតិសម្បទា និងអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដូចជា អង្គការ UNODC WHO UNAIDS USAID/ Cambodia HAARP UNICEF KHANA FI មិត្តសម្លាញ់ FHI ។

## III. ការសន្និដ្ឋាន និង វាយតម្លៃ

ដូចសភាពការណ៍និងលទ្ធផលការងារខាងលើ យើងបានកត់សំគាល់ដូចតទៅ :

-នៅលើការងារផ្សព្វផ្សាយអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន យើងបានបង្កើនកិច្ចសហការគ្នាបានល្អរវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយ ក្រសួង-ស្ថាប័ន អង្គការជាដៃគូជាតិ-អន្តរជាតិ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ពោលគឺយើងបានប្រើប្រាស់ស្ទើរគ្រប់កម្លាំងសរុបរបស់សង្គម និងអនុវត្តបានចំកន្លែង និងក្រុមជនគោលដៅដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ជាក់ស្តែងដូចជា ការផ្តល់នូវឯកសារពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀននឹងបញ្ហាអេដស៍ ដល់មហាវិទ្យាល័យ សាកលវិទ្យាល័យ របស់រដ្ឋនិងឯកជន សំរាប់បំរើឱ្យការសិក្សាស្រាវជ្រាវ ។ ការបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមសហគមន៏ សំរាប់អនុវត្តកម្មវិធីមិត្តអប់រំយុវជននៅក្រៅប្រព័ន្ធអប់រំ និងកម្មវិធីមិត្តអប់រំមិត្តនៅក្នុងសាលារៀន ជាដើម ដែលសកម្មភាពទាំងអស់ គប្បីបន្តធ្វើឱ្យបានជាប់ជាប្រចាំនិងឱ្យកាន់តែបានទូលំទូលាយនិងស៊ីជំរៅ ដើម្បីកាន់តែទទួលបាននូវប្រសិទ្ធភាព ។

ប៉ុន្តែក៏នៅមានបញ្ហាប្រឈមមួយចំនួនផងដែរ ដូចជា ក្នុងការរៀបចំឯកសារផ្សព្វផ្សាយអប់រំ ដែលមានលក្ខណៈជាអន្តរក្រសួង សំរាប់ប្រើប្រាស់នៅតាមគោលដៅផ្ទះសំណាក់ សណ្ឋាគារ កន្លែងកំសាន្តសប្បាយនានា រួមទាំងការអប់រំ ពន្យល់ណែនាំដល់ម្ចាស់ទីតាំងឬអ្នកគ្រប់គ្រងកន្លែងទាំងអស់នោះ ដើម្បីគេបានយល់និងចូលរួមចំណែកធ្វើសកម្មភាពអប់រំ បង្ការ ទប់ស្កាត់លើបញ្ហាគ្រឿងញៀន បញ្ហាអេដស៍ និងការអនុវត្តនីតិវិធានការរដ្ឋបាលផ្សេងៗ គឺនៅមានកំរិតនៅឡើយ ។

នៅលើការងារអនុវត្តច្បាប់ យើងបានពិនិត្យឃើញ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ប្រភេទនិងគ្រប់លំដាប់ថ្នាក់ បានបង្កើនសកម្មភាពក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀនដែលបានកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ធ្វើឱ្យការងារបង្ក្រាបបទល្មើសគ្រឿងញៀនទទួលបាននូវលទ្ធផលខ្ពស់ ។ ប៉ុន្តែយើងក៏បានពិនិត្យឃើញផងដែរ ចំពោះ បណ្តាខេត្តមួយចំនួនទៀតហាក់ដូចជានៅពុំទាន់បានប្រើប្រាស់វិធានការសរុបនិងកម្លាំងសរុបឱ្យអស់ពីលទ្ធភាព ក្នុងការស៊ើបអង្កេតស្រាវជ្រាវបង្ក្រាបបទល្មើសគ្រឿងញៀនដែលបានកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួននៅឡើយ ។

ដោយឡែក ការងារព្យាបាលនិងស្តារនីតិសម្បទា ដើម្បីអនុវត្តឱ្យបានសមស្របតាមតួនាទីនិងភារកិច្ចទទួលខុសត្រូវអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏បានប្រគល់ការគ្រប់គ្រងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទៅឱ្យក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ជាអ្នកទទួលខុសត្រូវបន្ត ដែលបច្ចុប្បន្នក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា កំពុងបន្តការរៀបចំលិខិតបទដ្ឋានមួយចំនួនបន្ថែមទៀត ដើម្បីបំពេញឱ្យអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១១

សេចក្តីដូចបានធ្វើការសន្និដ្ឋាននិងវាយតម្លៃពីសភាពការណ៏គ្រឿងញៀន និងចំណុចប្រឈមក្នុងការអនុវត្តន៏យុទ្ធសាស្ត្រខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានដាក់ចេញនូវទិសដៅសំរាប់អនុវត្តបន្តដូចខាងក្រោម :

១. បន្តកិច្ចសហការ សម្របសម្រួលជាមួយក្រសួងជាសមាជិក អជបគញ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ក្នុងការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន និងការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋនិងឯកជន ជាពិសេស តាមរយៈកម្មវិធីប្រចាំខែដែលផ្តល់ដោយស្ថានីយទូរទស្សន៍ CTN ។

២. បន្តកិច្ចសហការ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជម្រុញការរៀបចំផលិត Sticker សម្រាប់ផ្សព្វផ្សាយអប់រំនៅតាមគោលដៅដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ។

៣. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលនៅខេត្តព្រះសីហនុ ស្តីពីការពង្រឹងសមត្ថភាពអនុវត្តច្បាប់គ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ នៅថ្ងៃទី០១-០៤ ខែមីនា ឆ្នាំ២០១១ ។

៤. ត្រៀមរៀបចំប្រជុំវាយតម្លៃដកពិសោធន៍ លើការបង្រៀនសាកល្បងដល់មន្ត្រីអនុវត្តច្បាប់ ស្តីពីការពង្រឹងសមត្ថភាពអនុវត្តច្បាប់ និងការកាត់បន្ថយគ្រោះថ្នាក់ នៅថ្ងៃទី២១-២២ ខែមីនា ឆ្នាំ២០១១ ។

៥. រៀបចំបង្កើតយន្តការក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យ ការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀន នៅខេត្តកណ្តាល ។

៦. បន្តកិច្ចសហការ ជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ចំពោះការងារមួយចំនួនដែលពាក់ព័ន្ធនឹងការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៧. សហការ សម្របសម្រួល ជាមួយក្រសួងពាក់ពន្ធ័ ដើម្បីជំរុញការរៀបចំប្រកាស និង អនុក្រឹត្យ ដូចមានចែងក្នុងមាត្រា៣ មាត្រា៤ និង មាត្រា៦ នៃអនុក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៨. ត្រៀមការចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាបន្តលើសេចក្តីព្រាងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

៩. បន្តកិច្ចដំណើរការប៉ាន់ប្រមាណពីចំនួនអ្នកប្រើគ្រឿងញៀននៅកម្ពុជា ។

១០. យកចិត្តទុកដាក់ ត្រួតពិនិត្យ តាមដាន ការអនុវត្តន៍កម្មវិធីម្ជុល/ស៊ីរាំង ដែលបានអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនអនុវត្ត ។

១១. បន្តការរៀបចំបែបបទចុះឈ្មោះ ឱ្យមន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អជបគញ ចូលរួមក្នុងកម្មវិធី "កិច្ចសហការធ្វើកោសល្យវិច័យជាលក្ខណៈអន្តរជាតិ" ដែលរៀបចំដោយការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ ។

១២. បន្តការត្រៀមលក្ខណៈទទួលក្រុមប្រតិភូអង្គភាពត្រួតពិនិត្យគ្រឿងញៀនសហព័ន្ធរុស្ស៊ី ដែលអញ្ជើញមកធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់កម្ពុជា ។

១៣. បន្តកិច្ចសហប្រតិបត្តិការរៀបចំផែនការសកម្មភាពគំរោង កម្ពុជា-កូរ៉េ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៤. បន្តកិច្ចសហការជាមួយអង្គការUNODC ចុះសិក្សាស្វែងយល់ពីស្ថានភាពគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែន នៅច្រកទ្វារអន្តរជាតិត្រពាំងផ្លុង ខេត្តកំពង់ចាម នាថ្ងៃទី០២ខែមីនាឆ្នាំ២០១១ ។

១៥. ត្រៀមចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមប្រតិភូលេខាធិការដ្ឋានអាស៊ី ប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ ។

*- ការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន*

ដើម្បីអនុវត្តបានសម្រេចទិសដៅត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដោយផ្តោតសំខាន់ទៅលើ :

-ការជំរុញការរៀបចំយន្តការបង្កើត សាលារៀនពណ៌បៃតងគំរូគ្មានគ្រឿងញៀន ។

-ការជំរុញការរៀបចំផែនការជាតិ៥ឆ្នាំ(២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ការត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផល និងដកពិសោធន៍ការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន នៅខេត្តបន្ទាយមានជ័យ ។

-ការត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ និងទិសដៅការងារឆ្នាំ២០១១។

-ការបន្តកិច្ចសហការជាមួយក្រសួងផែនការ ជំរុញការរៀបចំប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀន ថ្នាក់ជាតិ ។

**អគ្គលេខាធិការស្តីទី**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អជបគញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ

# អង្គភាពដែលបានធ្វើការផ្សព្វផ្សាយអប់រំ
# ពីគ្រោះថ្នាក់នៃគ្រឿងញៀន ខែ កុម្ភៈ ឆ្នាំ ២០១១

| ឈ្មោះ<br>អង្គភាពសាមី | ឈ្មោះអង្គភាព<br>សហការសំរបសំរួល | ខ្លឹមសារផ្សព្វផ្សាយ គោលដៅ សមាសភាព | ចំនួនអ្នក<br>ចូលរួម |
|---|---|---|---|
| អង្គការពន្លឺកុមារកម្ពុជា | អជបគញ | -ចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាលជនបង្គោលបណ្តាញយុវជនសំរាប់គំរោងអន្តរាគមន៍ដើម្បីសុវត្ថិភាពសហគមន៍ មូលដ្ឋាន ដំណាក់កាលទី២ នៅឃុំព្រែករកា និង ឃុំអំពៅព្រៃ (៥២ នាក់)<br>-ចូលរួមវេទិកាពិភាក្សាយុវជនក្រោមប្រធានបទ រួមសាមគ្គីគ្នាធ្វើឲ្យសហគមន៍យើងមានសុវត្ថិភាព នៅស្រុកកណ្តាលស្ទឹង សរុប ៥០០ នាក់ | ៥៥២ នាក់ |
| កំពង់ចាម | | -ច្បាប់គ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន<br>(ស្រុកស្ទឹងត្រង់: ក្រុមប្រឹក្សាឃុំ នគរបាលប៉ុស្តិ៍ នាយកសាលា មេភូមិ ម្ចាស់ផ្ទះសំណាក់ ខារាអូខេ ប្រជាពលរដ្ឋ ៧៦ នាក់) | ៧៦ នាក់ |
| កំពង់ធំ | | -ច្បាប់គ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន<br>-ចុះចែកបំរាម ១៣៤ គ្រួសារ<br>(ស្រុកប្រាសាទសំបូរ:  ប្រជាពលរដ្ឋ ៧២៣ នាក់). (ក្រុង ស្ទឹងសែន: មេភូមិ សិក្ខាកាមផ្នែកសេវាកម្ម កសិកម្ម ប្រជាពលរដ្ឋ ១៨២ នាក់). (ស្រុកបារាយណ៍: គ្រូ សិស្ស ប្រជាជន ៣៩៨១ នាក់). (គណៈ.គ្រួត.គ្រ.ញខេត្ត ២៤៨ នាក់). | ៥.១៣៤ នាក់ |
| បាត់ដំបង | | -គ្រោះថ្នាក់នៃគ្រឿងញៀន និងមេរោគអេដស៍/ជម្ងឺអេដស៍<br>(ស្រុកថ្មគោល: ប្រជាជន ១.២៧៦ នាក់). (ស្រុកបវេល: ប្រជាជន ៣៥៣ នាក់). (ស្រុករតនមណ្ឌល:២៣៦ នាក់). | ១.៨៦៥ នាក់ |
| ប៉ៃលិន | សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ | -គ្រោះថ្នាក់នៃគ្រឿងញៀន បញ្ហាអេដស៍ បញ្ហាសុខភាពបន្តពូជ និងកាមរោគ<br>(កន្លែងសេវាកំសាន្ត: ៣៣២ នាក់). (ក្រុងប៉ៃលិន: មន្ទីរពាក់ពន្ធ័ ៥១ នាក់). | ៣៨៣ នាក់ |
| កំពង់ឆ្នាំង | | -ចុះបិទបម្រាម ហាមប្រើប្រាស់គ្រឿងញៀន នៅតាមសាលារៀន និងទីប្រជុំជន ១៨០សន្លឹក<br>-ផលប៉ះពាល់នៃគ្រឿងញៀន មេរោគអេដស៍ ជម្ងឺអេដស៍<br>(ស្រុកកំពង់ត្រឡាច: វិទ្យាល័យបន្ទាយលង្វែក លោកគ្រូ អ្នកគ្រូ សិស្ស ២៥៥ នាក់). (ស្រុកបរិបូណ៌ ២០ នាក់). | ២៧៥ នាក់ |
| កែប | | -គ្រោះថ្នាក់នៃគ្រឿងញៀន<br>(ក្រុងកែប: ប្រជាពលរដ្ឋ អ្នករត់ម៉ូតូកង់បី ៤៦៦ នាក់). (ស្រុកដំណាក់ចង្អើរ ប្រជាពលរដ្ឋ ៤៥៤ នាក់). | ៩២០ នាក់ |
| ព្រះវិហារ | អង្គការទស្សនៈពិភពលោកប្រចាំខេត្ត | -គ្រោះថ្នាក់នៃគ្រឿងញៀន<br>(ស្រុករវៀង: គ្រូ សិស្ស ប្រជាជន ៤៥២ នាក់). (ក្រុងព្រះវិហារ: ប្រជាជន ១.៦១០ នាក់). (ស្រុកជាំក្សាន្ត ១៩៨នាក់). | ២.២៦០ នាក់ |
| ក្រចេះ | | -ផលប៉ះពាល់នៃគ្រឿងញៀន មេរោគអេដស៍ ជម្ងឺអេដស៍<br>(ស្រុកសំបូរ: គ្រូ សិស្ស ១០៤ នាក់). | ១០៤ នាក់ |
| ស្ទឹងត្រែង | សមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទREDA ប្រចាំខេត្ត | -គ្រោះថ្នាក់នៃគ្រឿងញៀន<br>(ក្រុងស្ទឹងត្រែង: គ្រូ សិស្ស ឃុំ សង្កាត់ ២០ នាក់). | ២០ នាក់ |
| ព្រៃវែង | | -គ្រោះថ្នាក់នៃគ្រឿងញៀន<br>(ស្រុកកញ្ជ្រៀច: ប្រជាពលរដ្ឋ ១៧១ នាក់). | ១៧១ នាក់ |
| កណ្តាល | | -ច្បាប់គ្រឿងញៀន ច្បាប់ចរាចរណ៍ ក្មេងទំនើង<br>(ស្រុកកណ្តាលស្ទឹង: គ្រូ សិស្ស ប្រជាពលរដ្ឋ ៥៦៨ នាក់). | ៥៦៨ នាក់ |
| តាកែវ | | -ចុះបិទបំរាមហាមប្រើប្រាស់គ្រឿងញៀន២៧ កន្លែង | |
| | | សរុប | **១២.៣២៨ នាក់** |

# អង្គភាពបង្ក្រាបបទល្មើសគ្រឿងញៀន ក្នុងខែកុម្ភៈ ឆ្នាំ២០១១

| ល.រ | អង្គភាព | សរុបរួម | | | ផលិតចរាចរជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| *1* | *មន្ទីរប្រឆាំងគ្រឿងញៀន* | **2** | **6** | **1** | 2 | 6 | 1 | | | | | | |
| *2* | *ន.កណ្ដាលសន្តិសុខ* | **2** | **4** | **3** | 2 | 4 | 3 | | | | | | |
| *3* | *ន.ប ភ្នំពេញ* | **28** | **68** | **15** | 20 | 35 | 9 | 8 | 31 | 5 | 0 | 2 | 1 |
| *4* | *ន.បកណ្ដាល* | **1** | **8** | **1** | 1 | 8 | 1 | | | | | | |
| *5* | *ន.ប កំពង់ចាម* | **4** | **7** | **1** | 3 | 4 | 0 | 1 | 3 | 1 | | | |
| *6* | *ន.ប ព្រះសីហនុ* | **1** | **1** | **1** | 1 | 1 | 1 | | | | | | |
| *7* | *ន.ប ស្ទឹងត្រែង* | **0** | **1** | **0** | | | | | | | 0 | 1 | 0 |
| *8* | *ន.ប កំពត* | **1** | **5** | **0** | | | | 1 | 5 | 0 | | | |
| *9* | *ន.ប កោះកុង* | **1** | **3** | **1** | 1 | 3 | 1 | | | | | | |
| *10* | ន.ប បន្ទាយមានជ័យ | **3** | **5** | **3** | 3 | 5 | 3 | | | | | | |
| *11* | ន.ប ពោធិសាត់ | **0** | **1** | **0** | | | | | | | 0 | 1 | 0 |
| *12* | ន.ប ក្រចេះ | **1** | **1** | **0** | | | | 1 | 1 | 0 | | | |
| *13* | ន.ប ប៉ៃលិន | **2** | **3** | **3** | 2 | 3 | 3 | | | | | | |
| **សរុប** | | **46** | **113** | **29** | **35** | 69 | 22 | **11** | 40 | 6 | **0** | 4 | 1 |

# វត្ថុតាងចាប់យក រាយតាមអង្គភាព ក្នុងខែកុម្ភៈ ឆ្នាំ២០១១

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | *WY* (គ្រាប់) | *ICE* (ក្រាម) | *Heroine* (ក្រាម) | ម្សៅពណ៌ស (ក្រាម) | ម្សៅពណ៌ស គ្មានសារធាតុញៀន(ក្រាម) | | | | |
| *1* | **មន្ទីរប្រឆាំងគ្រឿងញៀន** | *7.843* | | | | | | | | |
| *2* | **ន.ដ្ឋាន.កណ្ដាលសន្តិសុខ** | *9.955* | | *388,70* | | | | | | |
| *3* | **ន.ប ភ្នំពេញ** | *138* | *69,25* | *0,02* | | *0,27* | | | | |
| *4* | **ន.ប កណ្ដាល** | | *57,30* | | | | | | | |
| *5* | **ន.ប កំពង់ចាម** | | *0,68* | | | | | | | |
| *6* | **ន.ប ព្រះសីហនុ** | *399* | *8* | | | | | | | |
| *7* | **ន.ប កោះកុង** | *42* | | | | | | | | |
| *8* | **ន.ប បន្ទាយមានជ័យ** | *777* | | | *1,4* | | | | | |
| *9* | **ន.ប ប៉ៃលិន** | *20* | | | | | | | | |
| | **សរុប** | ***19.174*** | ***135,23*** | ***338,72*** | ***1,4*** | ***0,27*** | | | | |

**វត្ថុតាងផ្សេងៗ  អាវុធខ្លី ២ ដើម, រថយន្ត ១ គ្រឿង, ម៉ូតូ ៣ គ្រឿង, ជញ្ជីង ៤ ៕**

# ទិន្នន័យសារធាតុគីមីផ្សំមានអាជ្ញាប័ណ្ណនាំចូល ប្រចាំខែ កុម្ភៈ ឆ្នាំ ២០១១

| ឈ្មោះសារធាតុគីមី | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | | | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|
| | Kg | L | Amp | Kg | L | Amp | Kg | L | Amp |
| Acetone | 6.000 | | | 12.160 | | | **18.160** | | |
| Ethyl Acetate | 5.000 | | | 32.160 | | | **37.160** | | |
| Methyl Ethyl Ketone | 500 | | | 31.100 | | | **31.600** | | |
| Toluene | 20.000 | | | 69.155 | | | **89.155** | | |
| Xylene | 134.500 | | | | | | **134.500** | | |
| Methyl Ethyl Chloride | 20.000 | | | | | | **20.000** | | |
| **Acide Acetic** | | | | 16.000 | | | **16.000** | | |
| Caustic Soda | | | | 88.250 | | | **88.250** | | |
| Soda Ash | | | | 376.000 | | | **376.000** | | |
| Glacial Acetic Acide | | | | 57.500 | | | **57.500** | | |
| Sodium Sulfate | | | | 952.000 | | | **952.000** | | |
| Formic Acide | | | | 25.000 | | | **25.000** | | |
| Methylene Chloride | | | | 31.850 | | | **31.850** | | |
| Solvent | | | | 12.564 | | | **12.564** | | |
| **TOTAL** | **186.000** | | | **1.703.739** | | | **1.889.739** | | |